| 4.3 | កសាងការបណ្តុះបណតាលសមត្ថភាព សំរាប់ កិច្ចសហប្រតិបត្តិការ ឆ្លងដែន | • ធ្វើការប៉ាន់ប្រមាណរកយន្តការឆ្លងដែននានា ដែលមានអត្ថិភាព នៅតាមច្រកព្រំដែន នានា និងប៉ាន់ប្រមាណរកសេចក្តីត្រូវការវិស័យផ្សេងៗៗទៀត ដែលត្រូវការយន្តការឆ្លងដែន | • ចែករំលែកការអនុវត្តល្អ និងការលំបាកក្នុងការកសាងសមត្ថភាព អ្នកជំរុញការអនុវត្តច្បាប់ និងតាមដានករណីទូទាំងប្រទេស<br>• សិក្ខាសាលាសំរេចកិច្ចព្រមព្រៀងលើស្តង់ដារ នៃនីតិវិធីប្រតិបត្តិការ សំរាប់ចែករំលែកពតិមាន និងការស៊ើបការណ៏ | • បំផុសបេសកកម្ម និងការ កសាង សមត្ថភាពទៅតាមសេចក្តីត្រូវការ និង សំណើ |
| 4.4 | វាយតម្លៃក្នុង ប្រទេសនីមួយៗ អំពីរបៀប ដែលនីតិ វិធីច្បាប់ និងគតិយុត្តិ ត្រូវបានអនុវត្ត ជាក់ស្តែង ដើម្បី ការពារជនរងគ្រោះ ព្រមទាំងឃាត់ខ្លួនជនល្មើស | • ចែករំលែកលទ្ធផលនៃ ការវាយតម្លៃ<br>• រៀបចំសិក្ខាសាលាថ្នាក់ជាតិដើម្បីកំណត់ និងកែសម្រួលអនុសាសន៏<br>• យុទ្ធសាស្ត្រជាក់លាក់របស់ប្រទេសក្នុងការកែលំអការចោទប្រកាន់ និងលទ្ធភាពទទួលបាន សំណងរដ្ឋប្បវេណីទៅតាមក្របខ័ណ្ឌច្បាប់ ដែលមានស្រាប់ នឹងត្រូវបានបង្កើត | • របាយការណ៏ជាក់លាក់ អំពីខមមីតដោយមានការចងក្រងទិន្នន័យសម្រាប់ ប្រទេសអនុតំបន់មេគង្គទាំង អស់<br>• លេខាធិការដ្ឋានសម្រាប់ផ្តល់ជំនួយបច្ចេកទេសដល់ក្រុមការងារខមមីត ក្នុងការកសាងយុទ្ធសាស្ត្រថ្នាក់ជាតិ នៅពេលមានសំណើ | • ការវាយតម្លៃកម្រិតជាតិ<br>• យុទ្ធសាស្ត្រជាក់លាក់របស់ ប្រទេសដើម្បីកែលំអការចោទប្រកាន់ និងលទ្ធភាពទទួល បានសំណងរដ្ឋប្បវេណី នៅក្រោមក្របខ័ណ្ឌច្បាប់ដែលបានបង្កើតឡើង និងធ្វើការវិភាគករណី នៅពេលមានការចាំបាច់ |

| | | | | |
|---|---|---|---|---|
| 4.5 | ភ្លាស់ប្តូរពតិមានស្តីពីនីតិវិធីចោទប្រកាន់.ច្បាប់ រួមមានភស្តុតាង ហើយនិងក្រិត្យក្រមភស្តុតាង | សិក្ខាសាលាថ្នាក់តំបន់ ផ្អែកលើការប៉ាន់ប្រមាណខាងលើ ក្នុងសកម្មភាព ៤.៤ | គាំទ្រការវិភាគលើរបកគំហើយដែលបានពីការប៉ាន់ប្រមាណ និងរៀបចំសិក្ខាសាលាតំបន់ | វិភាគ និងសំរបសំរួលនីតិវិធីច្បាប់ / ការចោទប្រកាន់នៅថ្នាក់ជាតិ |
| 4.6 | ពង្រឹងកិច្ចសហប្រតិបត្តិការលើការរៀបចំនីតិវិធីអនុវត្តច្បាប់ឱ្យបានប្រសើរ ដើម្បីនាំខ្លួនជនល្មើស ទៅកាន់តុលាការ ដោយសង្កត់លើកិច្ចសហប្រតិបត្តិការ | • ពិនិត្យមើលច្បាប់ជាតិ និងនីតិវិធីចោទប្រកាន់អំពើជួញដូរមនុស្ស ដោយមានការវិភាគប្រៀបធៀប ទូទាំងតំបន់<br>• សិក្ខាសាលាថ្នាក់តំបន់ សីពីការបង្កើតនីតិវិធីអនុវត្តច្បាប់មានប្រសិទ្ធភាព ដើម្បីនាំខ្លួនជនល្មើស ទៅកាន់តុលាការ ដោយសង្កតលើកិច្ចសហប្រតិបត្តិការ | សិក្ខាសាលាថ្នាក់តំបន់ីពីការ បង្កើតនីតិវិធីអនុវត្តច្បាប់មានប្រសិទ្ធភាព ដើម្បីនាំខ្លួន ជនល្មើស ទៅកាន់តុលាការ ដោយសង្កតលើកិច្ចសហប្រតិបត្តិការ | រៀបចំ និងសំរបសំរួលលើរាល់កិច្ចការដែលទាក់ទងនឹងដំណើការចោទប្រកាន់ផ្លូវច្បាប់នៅថ្នាក់ជាតិ |
| 4.7 | បង្កើតការតាមដាន ករណី និងប្រព័ន្ធ វិភាគដើម្បីកំណត់រកបទពិសោធន៍ក្នុងអតីតកាល និងដោះស្រាយឧបសគ្គចំពោះការឆ្លើយតបផ្នែកតុលាការ និងការចោទប្រកាន់ដែល មានប្រសិទ្ធិភាព និងមានលក្ខណៈសមស្រប ទៅលើអំពើជួញដូរមនុស្ស | • ពិនិត្យមើលសារឡើងវិញនូវប្រព័ន្ធតាមដានបច្ចុប្បន្ន<br>• សម្របប្រព័ន្ធតាមដានតាមតម្រូវការជាក់លាក់របស់ប្រទេស | ផ្តល់ជំនួយបច្ចេកទេស និង-ឬជំនួយហិរញ្ញវត្ថុ តាមសំណើ | • ប្រមូលព័តិមានស្តីពីរឿងក្តីជោគជ័យ និងមិនជោគជ័យ<br>• វិភាគកត្តានានាដែលបានរួមចំណែក ចំពោះជោគជ័យ ឬបរាជ័យ |
| 4.8 | បន្តការបង្កើត និងពង្រឹងក្របខ័ណ្ឌច្បាប់ជាតិ និងទ្វេភាគី រួមមាន ការផ្តល់ជំនួយច្បាប់ទៅវិញទៅមក MLAs | • ពិនិត្យមើលបត្យាប័នបច្ចុប្បន្ន និងការអនុវត្ត ព្រមទាំងសន្និសញ្ញា និងកិច្ចព្រមព្រៀងផ្តល់ជំនួយច្បាប់ទៅវិញទៅមកផង<br>• សិក្ខាសាលាអនុតំបន់ស្តីពីការពង្រីក និងការកែលំអ ការប្រើប្រាស់ជំនួយផ្នែកច្បាប់ទៅវិញទៅមក និងបត្យាប័នក្នុងករណីជួញ ដូរមនុស្ស<br>• អង្កេតអំពីវិសាលភាព និងការអនុវត្តន៍បញ្ញត្តិ នានា ក្រៅបូរណភាពដែនដីពាក់ព័ន្ធ នឹងបណ្តាប្រទេសខមមីត | • ការវាយតម្លៃប្រចាំ តំបន់នៅឆ្នាំ ២០០៩ ដើម្បីវិភាគថាតើក្របខ័ណ្ឌច្បាប់នៅថ្នាក់ជាតិ ១) ចាត់ទុកការជួញដូរ មនុស្សជាអំពើឧក្រិដ្ឋដែរឬទេ ២) ដាក់ ទោសទណ្ឌសមស្រប ដែរឬទេ ៣) ការពារ ជនរងគ្រោះដែរឬទេ និង ៤) គាំទ្រសាក្សី ៥) បង្កើតយុត្តាធិការទូលាយបំផុតដែរឬទេ<br>• សិក្ខាសាលាអនុតំបន់ ដើម្បីចែករំលែកព័តិមាន ស្តីពីការប្រើអាណត្តិច្បាប់ចំពោះការលាងលុយកខ្វក់ ក៏ដូចជា បញ្ញត្តិសម្រាប់ឃាត់ទុក និងដកហូតសម្បត្តិទ្រព្យរបស់ជនល្មើស និងផ្តល់ប្រាក់សំណងដល់ជនរងគ្រោះ | • បន្តគាំទ្រដល់ការពង្រឹងក្របខ័ណ្ឌ ច្បាប់<br>• បង្កើតកម្មវិធីប្រចាំប្រទេស ដើម្បីបង្កើត និងធ្វើវិសេធនកម្មកិច្ចព្រមព្រៀង និងនីតិវិធី នានា នៅក្នុងប្រទេសក្នុងអនុតំបន់មេគង្គ តាមការចាំបាច់<br>• បន្តសិក្ខាសាលាស្តីពីការធ្វើវិសេធនកម្មកិច្ចព្រមព្រៀងជំនួយច្បាប់ទៅវិញទៅមក |

## PPC5–ការកំណត់អត្តសញ្ញាណជនរងគ្រោះ កិច្ចការពារ ការស្តារនីតិសម្បទា និងសមាហរណកម្ម

### គោលបំណង

• ដើម្បីបង្កើតលក្ខណៈវិនិច្ឆ័យដែលអាចទទួលយកបានទៅវិញទៅមកចំពោះនីតិវិធីកំណត់អត្តសញ្ញាណជនរងគ្រោះ ដើម្បីឱ្យមានការធ្វើមាតុភូមិនិវត្តន៍ជនរងគ្រោះដោយសារការជួញដូរមានប្រសិទ្ធភាព និងស្របតាមស្តង់ដារ ដែលមានចែងនៅក្នុងអនុស្សរណៈខមមីត និងឧបករណ៍អន្តរជាតិដទៃទៀត ដែលមានយោង នៅក្នុងអនុស្សរណៈនោះ ។

• ដើម្បីបង្កើនកំរិត និងគុណភាពនៃការឧបត្ថម្ភគាំទ្រជនរងគ្រោះដោយអំពើជួញដូរមនុស្ស ក៏ដូចជាសេវាកម្មផ្តត់ផ្តង់ ទាំងឡាយផងដែរ តាមរយៈអត្តសញ្ញាណកម្ម ការថែទាំបណ្តោះអាសន្ន ការវិលត្រឡប់,មាតុភូមិនិវត្តនិងដំណើរការស្តារនីតិសម្បទា និងដើម្បីបង្កើនការគាំទ្រសេដ្ឋកិច្ចសង្គមចំពោះជនរងគ្រោះ

### ស្ថានភាព PPC5 នៅចុង SPA I

PPC5 បានមកពីការដាក់បញ្ចូលនូវរាល់សកម្មភាពការពារជនរងគ្រោះនៅ SPAI ដែលពីមុននេះស្ថិតនៅលើចំណុច PPC2 ជាមួនឹង PPC6 (មាតុភូមិនិវត្តមានប្រសិទ្ធភាព និងទាន់ពេលវេលា) ហើយនិង PPC7 (ការគាំទ្រ ក្រោយពេលរងគ្រោះ) ។ PPC5 នៃ SPAII បានប្រមូលផ្តុំយកសមាសភាពនៃការឆ្លើយតប ខាងកិច្ចការពារជនរងគ្រោះទាំងអស់មកដាក់បញ្ចូលគ្នា នៅលើ PPC តែមួយ ។ ប្រកបដោយកិច្ចប្រឹងប្រែង ក្នុងការបង្កើតកិច្ចព្រមព្រៀងច្បាស់លាស់ រវាងបណ្តាប្រទេស ក្នុងមហាអនុតំបន់ ទៅលើការគាំទ្រ និងផ្តល់សេវាកម្មចំពោះជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដោយធ្វើយ៉ាងណាឱ្យមានជីវភាពប្រសើរ ក្នុងការស្តារនីតិសម្បទា និងសមាហរណកម្ម ដោយជោគជ័យ និងដើម្បីកាត់បន្ថយភាពងាយនឹងទទួលរងនូវការជួញដូរម្តងទៀត ។

នៅតំណាក់កាល SPAI ក្រុមការងារបានធ្វើការជាមួយគ្នា លើសមាសភាពការពារជនរងគ្រោះទាំងអស់ រួមមានអត្តសញ្ញាណកម្មជនរងគ្រោះ ការថែទាំ និងការពារបណ្តោះអាសន្ន ការផ្តល់ជំរក និងស្តារនីតិសម្បទាហើយនឹងការធ្វើសមាហរណកម្ម ។ មានការទទួលស្គាល់ថាបញ្ហាលំបាកចម្បងមួយចំពោះការធ្វើសមាហរណកម្មគឺថាជនរងគ្រោះច្រើនតែធ្លាក់ទៅក្នុងបរិយាកាសដូចគ្នានឹងបរិយាកាសកាលពីពួកគេចាកចេញទៅ អមដោយភាពងាយរងគ្រោះយ៉ាងនេះ ដូចជាខ្វះនូវការធានាផ្នែកសេដ្ឋកិច្ច និង-ឬខ្វះឱកាសអប់រំវិជ្ជាជីវៈ។ ក្នុងន័យនេះកត្តាជាច្រើននៃភាពងាយរងគ្រោះ ដែលពាក់ព័ន្ធជាមួយការធ្វើសមាហរណកម្ម ក៏មានទំនាក់ទំនងជាមួយការបង្ការផងដែរ ។ ប្រទេសខមមីតទទួលស្គាល់ថាវិធីសាស្ត្រថ្មី ដ៏ស្រួចស្រាវ សំរាប់ការធ្វើសមាហរណកម្ម ការបង្ការទប់ស្កាត់ និងការដោះរកភាពងាយរងគ្រោះ គឺជាសេចក្តីត្រូវការចាំបាច់ ។

**ចំណុចចៅនៅចុងបញ្ចប់នៃឯកសារ SPA ទី២ ( ២០០៨-២០១០ )**

- ការផ្លាស់ប្តូរគោលនយោបាយ និងនីតិវិធីនៅថ្នាក់ទ្វេភាគី និងនៅថ្នាក់ជាតិត្រូវបានអនុវត្ត ដើម្បីដោះស្រាយចំណុច ខ្វះចន្លោះសំខាន់ៗក្នុងការកសាងសមត្ថភាព និងហេដ្ឋារចនាសម្ព័ន្ធនៃកម្មវិធីអំពីការស្តារឡើងវិញ និង ការធ្វើសមាហរណកម្ម
- ការដាក់ឱ្យដំណើរការនៅថ្នាក់ជាតិ នូវសេចក្តីណែនាំថ្នាក់តំបន់ស្តីពីការការពារ ត្រូវបានបំពេញគ្រប់ជ្រុងជ្រោយ រាប់ទាំងការកំណត់អត្តសញ្ញាណជនរងគ្រោះផងដែរ ។
- ការផ្លាស់ប្តូរគោលនយោបាយ និងនីតិវិធី នៅថ្នាក់ជាតិ និងថ្នាក់ទ្វេភាគី ត្រូវបានអនុវត្ត ដើម្បីស្វែងរកដំណោះស្រាយ លើកិច្ចប្រឹងប្រែងក្នុងការរៀបចំគោលការណ៍ណែនាំស្តីពីការស្តារនីតិសម្បទា សមាហរណកម្ម និងមាតុភូមិនិវត្ត បច្ចុប្បន្ន ។

| | សកម្មភាព | ជំហានពាក់ព័ន្ធនានា | ការបែងចែកសកម្មភាពការពារ | |
|---|---|---|---|---|
| | | | នៅថ្នាក់តំបន់ | នៅតាមប្រទេស |
| 5.1 | • ការអនុវត្ត/ប្រតិបត្តិការថ្នាក់ជាតិ និងទ្វេភាគី លើគោលការណ៍ណែនាំ ណែនាំទូទៅចំពោះការ លើការ ការពារជនរងគ្រោះ" | • កិច្ចប្រជុំថ្នាក់ជាតិ ដើម្បីពិនិត្យមើល គោលការណ៏នៃនាំដែលមានស្រាប់ នៅថ្នាក់ ជាតិ ដើម្បីសម្របតាមគោលការណ៏ណែនាំ ថ្នាក់តំបន់ ដែលបានរៀបចំសេចក្តីព្រោង នេះឡើង ដោយរដ្ឋាភិបាល ខមមីត នៅក្នុង តំណាក់កាល SPAI<br>• បង្កើតគោលការណ៏ណែនាំ ទ្វេភាគី និងថ្នាក់ជាតិ ដោយសំរបតាមគោលការណ៏ណែនាំអនុតំបន់ស្តីពី ការការពារជនរងគ្រោះ<br>• ពិនិត្យមើល និងសម្របគោលការណ៏ នៃនាំ ស្តីពីការការពារ នៅថ្នាក់នាយកដ្ឋាន ដោយដាក់បញ្ចូលនូវផ្នែកសំខាន់ៗទៅ ក្នុងការបង្រៀនបុគ្គលិក នីតិវិធីប្រតិបត្តិ និងពិធីសារ<br>• ការកែលំអគោលការណ៏ណែនាំថ្នាក់ ជាតិ ពិសេសសម្រាប់ផ្នែក សំខាន់ៗ: ការកំណត់អត្តសញ្ញាណជនរងគ្រោះ ( ប្រទេសគោលដៅ) ជម្រក ស្នាក់នៅ និងការស្តារនីតិ សម្បទា ការបញ្ជូនត្រឡប់<br>• សិក្ខាសាលាថ្នាក់ជាតិស្តីពី យុទ្ធសាស្ត្រសម្រាប់បង្កើត ប្រព័ន្ធសម្រាប់កែលំអការ ការពារជនរងគ្រោះ និង សម្រួលការអនុវត្តន៏សេចក្តី នៃនាំ<br>• សិក្ខាសាលាទ្វេភាគី និងការ ផ្លាស់ប្តូរបច្ចេកទេសឆ្លងដែន ដើម្បីបង្កើត និងពង្រឹងសហ ប្រតិបត្តិការដែលដំណើរការ ក្នុងការការពារ និងការបញ្ជូន ដែលមានសុវត្ថិភាព និង បាន ទាន់ពេលវេលានូវជនរងគ្រោះដោយសារការ ជួញដូរ — *ជា ពិសេសការកំណត់អត្តញ្ញាណ ជនរងគ្រោះ ( ប្រទេសគោល* | • បកប្រែសេចក្តីព្រាងណែនាំទៅជា ភាសាជាតិ<br>• ផ្តល់ការគាំទ្របច្ចេកទេស និង ហិរញ្ញវត្ថុ ដើម្បីសម្រួលដំណើរការ ការពិនិត្យមើល ថ្នាក់ជាតិ ក្រុមការងាររៀបចំសេចក្តីព្រាង និងធ្វើឱ្យទៅជាការប្រតិបត្តិ<br>•<br>• ផ្តល់ជំនួយបច្ចេកទេស និងជំនួយ ហិរញ្ញវត្ថុ លើការសំរបសំរួល ការវិលត្រឡប់ និងការកសាង សមត្ថភាព | • ផ្សព្វផ្សាយកោលការណ៏ណែនាំអនុ តំបន់ទៅកាន់ក្រសួង-នាយក ដ្ឋានពាក់ព័ន្ធ ហើយ និង បង្រួបបង្រួមការពិនិត្យ មើល គោលការណ៏នៃនាំ ថ្នាក់ជាតិ ទាំងឡាយណា ដែលផ្ទុយពីគោលការណ៏ ណែនាំតួបន់<br>• ធ្វើការសំរបសំរួលការប៉ាន់ប្រមាណរួមរបស់រដ្ឋាភិបាល និងការកែសំរួលគោលការណ៏ណែនាំថ្នាក់ជាតិ ស្តីពីការការពារជនរងគ្រោះ ជាពិសេសការធ្វើអត្តសញ្ញាណកម្មជនរងគ្រោះ (នៅប្រទេសគោលដៅ) ការថែទាំបណ្តោះអាសន្ន ការស្តារនីតិសម្បទា និងការ វិលត្រឡប់ជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស<br>• ធ្វើការអនុម័តជាផ្លូវការនូវ គោលការណ៏ណែនាំស្តីពីអត្តសញ្ញាណកម្មជនរងគ្រោះ (តំបន់គោលដៅ) ការថែទាំបណ្តោះអាសន្ន ការស្តារនីតិសម្បទា និងការ វិលត្រឡប់ជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស<br>• បង្កើនកិច្ចសំរបសំរួលអន្តរទីភ្នាក់ងារ (ប្រព័ន្ធបញ្ជូន ) និង បង្កើតយុទ្ធសាស្ត្រអនុវត្តថ្នាក់ ជាតិ ដើម្បីការអនុវត្ត ការធ្វើ អត្តសញ្ញាណកម្ម ជនរងគ្រោះ (នៅប្រទេសគោលដៅ) ដើម្បីការថែរក្ស បណ្តោះ អាសន្ន ការស្តារនីតិសម្បទា និងការធ្វើមាតុភូមិនិវត្ត ជនរងគ្រោះដោយអំពើជួញដូរ |

| | | | | |
|---|---|---|---|---|
| | | | | មនុស្ស<br>• បង្កើតយន្តការពិនិត្យមើល និងចែក រំលែកពតិមាន តេវភាគី ជាមួយនឹងសមភាគី នៃរដ្ឋាភិបាលពាក់ព័ន្ធ<br>•<br>• ការធ្វើសកម្មភាពផ្តួចផ្តើមការបណ្តុះបណ្តាលសមត្ថាព អន្តរទីភ្នាក់ងារ ដើម្បី ពង្រឹង វិធានការការពារជនរងគ្រោះ |

| | | | | |
|---|---|---|---|---|
| 5.2 | • ធ្វើការប្រៀបធៀបលក្ខណវិនិច្ឆ័យ ឬស្តង់ដារ នៃការធ្វើអត្តសញ្ញាណកម្មជនរងគ្រោះ នៅក្នុងក្របខ័ណ្ឌច្បាប់ជាតិ នៃប្រទេសមហាអនុតំបន់ | • ធ្វើការវិភាគ និងរៀបចំសិក្ខាសាលា ដើម្បីបង្កើនការយល់ដឹងរបស់ប្រទេសទាំងអស់ ថាតើធ្វើយ៉ាងណា ដើម្បីកំណត់អំពើជួញដូរមនុស្សឱ្យបានជាក់លាក់ ហើយថាតើអ្នកណាដែលមានលក្ខណៈសម្បត្តិជាជនរងគ្រោះ នៅក្នុងប្រទេសមហាអនុតំបន់ | • សិក្ខាសាលាថ្នាក់តំបន់ ដើម្បីចែករំលែកបទពិសោធន៍ លើយន្តការ សំរាប់កាប្រមែប្រមូលយក និងការធ្វើអត្តសញ្ញាណកម្មជនរងគ្រោះ នៅពាសពេញមហាអនុតំបន់មេកង្គ | • ធ្វើការវិភាគ និងរៀបចំរបាយការណ៍ជាតិស្តី ពីការកំណត់ពីអំពើជួញដូរមនុស្ស និងការធ្វើអត្តសញ្ញាណកម្មជនរងគ្រោះ បានជាក់លាក់ករិតណា |
| 5.3 | • បង្កើតនិងពង្រឹងកិច្ចការពារផ្លូវច្បាប់ដល់ជនរងគ្រោះ ក្រុមគ្រួសារ សាក្សី និងអ្នកផ្តល់ដំណឹង | • ធ្វើឱ្យបានប្រសើរឡើងនូវគោលនយោបាយ និតិវិធិ និងការប្រតិបត្តិក្នុងការការពារផ្លូវច្បាប់ដល់ជនរងគ្រោះ ក្រុមគ្រួសារ សាក្សី និងអ្នកផ្តល់ដំណឹង | • ផ្អែកទៅលើសំណើ ផ្តល់ការគាំទ្របច្ចេក - ទេស និងហិរញ្ញវត្ថុ ព្រមទាំងការចែករំលែកបទពិសោធន៍អនុតំបន់ផង | • វិភាគករណីដើម្បីស្វែងយល់ពីចំណុចខ្លាំងនិងចំណុចខ្សោយ ក្នុងការការពារជនរងគ្រោះ និងសាក្សី<br>• វិភាគលើគោលនយោបាយ ដើម្បីស្វែងយល់ថាតើគោលនយោបាយ ទាំងនោះគួរត្រូវកែប្រែយ៉ាងណាដើម្បីធ្វើឱ្យកិច្ចការពារជនរងគ្រោះ បានប្រសើរឡើង |
| 5.4 | • ការផ្លាស់ប្តូរគោលនយោបាយ និងនីតវិធីទ្វេភាគី និងថ្នាក់ជាតិ ដើម្បីដោះស្រាយចំណុចខ្វះចន្លោះផ្នែកប្រតិបត្តិ និងសម្របសម្រួល | • កម្មវិធីកសាងសមត្ថភាពថ្នាក់ជាតិសម្រាប់មន្ត្រីរដ្ឋាភិបាល និងមិនមែនរដ្ឋាភិបាល ដែលធ្វើការជាមួយជនរងគ្រោះ ដោយសារការជួញដូរ | • តាមសំណើ ផ្តល់មតិ ផ្នែកបច្ចេកទេស និងគាំទ្រការរៀបចំ និងបង្កើតការបណ្តុះបណ្តាល | • ផ្តល់អាណត្តិការងារ និងផ្តល់ធន ធានចំពោះការដាក់បញ្ចូលបញ្ញត្តិបណ្តុះបណ្តាលការការពារជាក់លាក់ចំពោះជនរងគ្រោះនៅតាមបណ្តាក្រសួងពាក់ព័ន្ធ |

**PPC6 -វិធានការបង្ការ**

**គោលបំណង**

ដើម្បីបង្កើនកិច្ចសហប្រតិបត្តិការបង្ការអំពើជួញដូរមនុស្ស និងការកេងប្រវ័ញ្ចា កាត់បន្ថយភាពងាយរងគ្រោះក្នុងអំពើជួញដូរមនុស្ស និងការបង្ក្រាប ទៅលើរបៀបរការបែបកេងប្រវ័ញ្ច និងល្មើសច្បាប់ ។

**ស្ថានភាព PPC6 នៅចុងបញ្ចប់នៃ SPA I**

PPC6 នេះ ជាការពង្រីកចេញពី PPC8 នៃ SPAI ដំណោះស្រាយចំពោះរបៀបរការបែបកេងប្រវ័ញ្ច ។ PPC នេះត្រូវបានពង្រីក ដើម្បីដាក់បញ្ចូលវិធានការបង្ការ ដទៃទៀត ក្នុងការប្រយុទ្ធនឹងអំពើជួញដូរមនុស្សឱ្យស្រប តាមអនុស្សរណៈខមមីត ។ ដូច្នោះ ឥលូវនេះ PPC នេះ សំដៅលើកកំពស់ការយល់ដឹង ការដៅរក និងកាត់បន្ថយភាពងាយរងគ្រោះ ហើយនឹងការបង្ការនៅឯភាគីប្រភពបញ្ជូន ក៏ដូចជាភាគីគោលដៅ ។ លើសពីនេះទៅទៀតដើម្បីដោះស្រាយលើការប្រើវិធីរត់ការការងារបែបកេងប្រវ័ញ្ច ហើយនឹងសេវាកម្មបញ្ជូន ពលករទៅឱ្យឈ្មួញមនុស្ស ។ ដូចមុនដែរ ដំណោះស្រាយចំពោះរបៀបរការបែបកេងប្រវ័ញ្ច រួមមានភ្នាក់ងារ ដែលមានលក្ខណៈផ្លូវការច្រើន ដែលមានបំណងនឹងប្រតិបត្តិការតាមរយៈមធ្យោបាយច្បាប់ ឬពាក់កណ្តាលច្បាប់ ក៏ដូចជាអ្នករត់ការមុខរបរខ្នាតតូច នៅថ្នាក់មូលដ្ឋាន ដែលហាក់ដូចជាហួសពីខថែងរបស់គោលការណ៍ / បទបញ្ជានានា ។

**សកម្មភាពជាអាទិភាពនៃ PPC នេះ រួមមាន:**

- ការស្រាវជ្រាវ និងវិភាគ ដោយមានការប្រៀបធៀប ទោលើការជ្រើសរើសពលករ ចំណាកស្រុកតាម ឬក្រៅផ្លូវការ និងការរត់ការ
- ការបង្កើតគោលការណ៍ណែនាំថ្នាក់តំបន់អំពីការជ្រើសរើសពលករចំណាកស្រុក នៅអនុតំបន់មេគង្គ
- ការបង្កើនសមត្ថភាព និងការចូលរួមរបស់ក្រសួងការងារ ដើម្បីធ្វើនិយ័តកម្មប្រតិបត្តិការទាំងនេះ
- វិធានការដោយផ្ទាល់ ដើម្បីកាត់បន្ថយភាពងាយរងគ្រោះនៅក្នុងដំណើរការចំណាកស្រុក និងនៅក្នុងដំណើរការជ្រើសរើស និងនៅតាមកន្លែងធ្វើការងារ នានា
- ព្រមទាំងកិច្ចសហប្រតិបត្តិការកាន់តែជិតស្និទ្ធ រវាងប្រទេសបញ្ជូន និងប្រទេសទទួល ក្នុងការតាមដានលក្ខ័ណ្ឌការងាររបស់ពលករចំណាកស្រុក ។

កិច្ចប្រឹងប្រែងកាត់បន្ថយភាពងាយរងគ្រោះ និងការទប់ស្កាត់អំពើជួញដូរមនុស្ស នៅប្រទេសប្រភពដើម

ប្រទេសគោលដៅ និងច្រកព្រំដែន ។

**ចំណុចដៅសំរាប់ SPA II (២០០៨-២០១០)**

- ការបង្កើត និងការអនុវត្តន៍គោលការណ៍ណែនាំប្រតិបត្តិនៅថ្នាក់តំបន់ និងនៅថ្នាក់ជាតិ ព្រមទាំងយន្តការសម្រាប់ជ្រើសរើស និងការពារពលករចំណាកស្រុក
- ការបណ្តុះបណ្តាល និងការតាមដានដែលមានលក្ខណៈជាប្រព័ន្ធអំពីការអនុលោមតាមគោលការណ៍ណែនាំថ្នាក់តំបន់ និងថ្នាក់ជាតិស្តីពីការជ្រើសរើសពលករ និងការការពារពលរដ្ឋចំណាកស្រុក
- លើកកំពស់វិធានការចំៗ ដើម្បីកំណត់ចំណុចដៅ និងកាត់បន្ថយភាពងាយរងគ្រោះ នៅចំណុចក្តៅនៃប្រភពបញ្ជូន នៅតាមកន្លែងធ្វើការងារ ក៏ដូចជានៅតាមដំណើរការចំណាកស្រុក និងដំណើរការជ្រើសរើស

| | សកម្មភាព | ជំហានពាក់ព័ន្ធនានា | ការបែងចែកសកម្មភាព | |
|---|---|---|---|---|
| | | | នៅថ្នាក់តំបន់ | នៅតាមប្រទេស |
| 6.1 | ពង្រឹងវិធានការកាត់បន្ថយភាពងាយរងគ្រោះ ក្នុងអំពើជួញដូរ មនុស្ស | • ដោះរក និងគាំទ្រកម្មវិធី កាត់បន្ថយភាពក្រីក្រ និង បង្កើនឱកាសសេដ្ឋកិច្ច<br>• គាំទ្រការអប់រំ និងការបណ្តុះ បណ្តាលជំនាញ<br>• ផ្តល់ការធ្វើឯកសារផ្ទាល់ខ្លួនផ្លូវច្បាប់ចាំបាច់ រួមានការចុះបញ្ជីកំណើត | ផ្តល់មូលនិធិ និងការគាំទ្របច្ចេកទេស ដើម្បីផ្តោតការងារអោយដល់ជនគោលដៅដែលងាយទទួលរងគ្រោះ | • ផ្តោតការងារលើការកាត់បន្ថយភាពក្រីក្រ ការផ្តល់អាហាររូបករណ៍ ការអភិវឌ្ឍន៍សេដ្ឋកិច្ច ការចុះបញ្ជីកំណើត និងការធ្វើអន្តរាគមន៏ដទៃទៀត ដែលចាំបាច់ |
| 6.2 | បង្កើតប្រព័ន្ធឃ្លាំមើល និងការពារសហគមន៏ទោលើក្រុមងាយរងគ្រោះ និង ប្រថុយប្រថាន និងបង្កើតវិធានការបង្ការទប់ស្កាត់មានប្រសិទ្ធភាព នៅថ្នាក់ជាតិ និងមូលដ្ឋាន | • ដោះរកភាពងាយរងគ្រោះ នៅថ្នាក់សហគមន៏ ដើម្បីការធ្វើអត្តសញ្ញាណកម្ម និងផ្តល់អន្តរាគមន៏ដល់អ្នកងាយរងគ្រោះបានលឿន<br>• កសាងសមត្ថភាពមន្ត្រីប្រតិបត្តិការ ការឆ្លើយតបនឹងការជួញដូរមនុស្សជួរមុខ និងអ្នកឃ្លាំមើលក្នុងប្រព័ន្ធត្រួតពិនិត្យ | ផ្តល់ការគាំទ្របច្ចេកទេស ហិរញ្ញវត្ថុ | • បង្កើតវិធីសាស្តដោះរកភាពងាយរងគ្រោះ និង កត្តានៃការថ្រុយប្រថាន ដែលប្រែប្រួលទៅតាមមជ្ឈដ្ឋាន<br>• កសាងសមត្ថភាពក្រុមការងារជាតិ និងមូដ្ឋាន ដើម្បីកំណត់លើងនូវរបាយការណ៍ស្តីពីភាពងាយរងគ្រោះ និងការជួញដូរមនុស្ស ជាសក្តានុពល |
| 6.3 | លើកកំពស់ការយល់ដឹងទាក់ទងនឹងអំពើជួញដូរមនុស្សគ្រប់លំដាប់ ថ្នាក់ | • យុទ្ធនាការផ្សព្វផ្សាយពតិមាន និងតស៊ូមតិទាក់ទងនឹង គ្រោះថ្នាក់ព្រមទាំងផលប៉ះពាល់អវិជ្ជមានដែលកើតមកពីអំពើជួញដូរមនុស្ស និងអំពីជំនួដែលអាចស្វែងរកបានចំពោះជនរងគ្រោះ | ផ្តល់ការគាំទ្របច្ចេកទេស ហិរញ្ញវត្ថុ | លើកកំពស់ការយល់ដឹងជាសាធារណៈ នៅតាមគោកដៅ |
| 6.4 | ពង្រីកការអនុវត្តច្បាប់ការងារជាតិ ក្នុងការការពារសិទ្ធិកម្មករ ដោយផ្អែកលើកោលការណ៏មិនរើសអើង និងស្មើភាព | • ការស្រាវជ្រាវពហុប្រទេស លើការជ្រើសរើសពលករចំណាកស្រុកតាមផ្លូវការនិងក្រៅផ្លូវការ ព្រមទាំងការប្រើប្រាស់របៀបរត់ការ | • ផ្តល់ការគាំទ្របច្ចេកទេស ហិរញ្ញវត្ថុធ្វើសេចក្តីព្រាងកម្មវិធីបណ្តុះបណ្តាល<br>• រៀបចំសេចក្តីព្រាងកម្មវិធី និងធ្វើកម្មវិធីបណ្តុះ | • ជួយដល់ការអនុវត្ត និងវិភាគលើរបកគំហើញនៃការស្រាវជ្រាវ<br>• ធ្វើការស្រាវជ្រាវរកជនរងគ្រោះ ដោយការកេងប្រវ័ញ្ចន៏<br>• ផ្សព្វផ្សាយពតិមានទៅទូទាំងប្រទេស |

| | | | | |
|---|---|---|---|---|
| | | • វគ្គបណ្តុះបណ្តាលថ្នាក់តំបន់ស្តីពីការអនុវត្តគោលការណ៍នែនាំតំបន់ក្នុងការជ្រើសរើសពលករចំណាកស្រុក<br>• ពង្រឹងការអនុវត្តការតាមដានការងាររួមមានការផ្សាភ្ជាប់កិចការរវាងអធិការព្រំដែន និងភ្នាក់ងារជំរុញការអនុវត្តច្បាប់ដទៃទៀត | បណ្តាល គ្រូបង្គោលថ្នាក់តំបន់<br>• បង្កើតក្របខ័ណ្ឌសហប្រតិបត្តិការតំបន់ រវាងក្រសួងការងារ និយោជក និងអង្គការនិយោជិត<br>• កិច្ចប្រជុំអនុតំបន់ ដើម្បីចែករំលែកបទពិសោធន៍ និង ពិភាក្សាអំពីតួនាទីក្រសួងការងារក្នុងការប្រយុទ្ធនឹង អំពើជួញដូរមនុស្ស<br>• គាំទ្រការបណ្តុះបណ្តាល និង និងការបណ្តុះបណ្តាលក្នុងការងារជូនដល់អធិការការងារ និងការរត់ការ | • ធ្វើការបណ្តុះបណ្តាលថ្នាក់ចាតិ<br>• គិច្ចពិគ្រោះយោបល់ថ្នាក់ចាតិដើម្បីបនិត្យមើលការអនុវត្តដែលមានអត្ថិភាព និងស្នើលើងនូវការផ្សាភ្ជាប់ជាមួយនឹងភ្នាក់ងារពង្រឹងការអនុវត្តច្បាប់<br>• រៀបចំកិច្ចប្រជុំថ្នាក់ចាតិដើម្បីបិនិត្យមើលរបកគំហើញ និងកំណត់ជំហ៊ាននៃការពង្រឹងក្របខ័ណ្ឌនៃការត្រួតពិនិត្យសកម្មភាពរត់ការបែបកេងប្រវ័ញ្ច |
| 6.5 | បង្កើត និងអនុវត្តគោលការណ៍នែនាំ អនុតំបន់ស្តីពីការជ្រើរើសកម្មករចំណាករសុក នៅក្នុងមហាអនុតំបន់មេគង្គ | បង្ហើយ និងផ្សព្វផ្សាយ គោលការណ៍ណែនាំ | • សិក្ខាសាលាតំបន់ស្តីពីការបង្កើតគោលការណ៍ណែនាំ ថ្នាក់តំបន់<br>• ផ្តល់ការគាំទ្របច្ចេកទេស ហិរញ្ញវត្ថុតាមសំណើ | • សំរបសំរួលការតាមដានថ្នាក់ជាតិ<br>• កសាងសមត្ថភាមន្ត្រីរដ្ឋាភិបាល កម្មករ និងអង្គការនិយោជកអង្គការ ស្តីពីការអនុវត្តការជ្រើសរើសនិងលទ្ធផលនៃការកេងប្រវ័ញ្ចដែលអាចកើតមាន<br>• បង្កើតតេស្តសាកល្បង និងផ្សព្វផ្សាយការផ្សាភ្ជាប់ពតិមានការងារដើម្បីប្រើប្រាស់ក្នុងដំណើរការជ្រើសរើស និង នៅតាមកន្លែងធ្វើការ ជាភាសាសមស្រប<br>បង្កើត និងផ្សព្វផ្សាយជនបង្គោលសំរាប់ការចុះឈ្មោះអ្នករត់ការមុខរបរ ទាំងភ្នាក់ងារអាពាហ៏ពិពាហ៏ និងស្មុំកូនចិញ្ចឹមងដែលមានចុះបញ្ជី ឬដែលបានទទួលអាជ្ញាប័ណ្ណស្របច្បាប់<br>• ផ្តល់សេវា ដូចជា ការផ្សព្វផ្សាយ ការចុះបញ្ជី ជំនួយផ្នែកច្បាប់ និងសេវា ដទៃទៀត នៅកន្លែងធ្វើការងារ និងសហគមន៏ទិសដៅ<br>• ពង្រឹងយន្តការដាក់ពាក្យប្តឹងសម្រាប់កម្មករ និងបេក្ខជនដែលដាក់ពាក្យសុំ ការងារធ្វើ<br>• ធ្វើការបោះពុម្ពផ្សាយព័តិមានអំពី សកម្មភាព របស់ មនុស្សនិងក្រុមហ៊ុនដែលត្រូវបានសង្ស័យថា ពាក់ព័ន្ធនឹងការជួញដូរមនុស្ស |

| | | | | |
|---|---|---|---|---|
| | | | | ឱ្យទាន់សភាពការណ៍ និងជាទៀងទាត់ ។ |
| 6.6 | បង្កើតកញ្ចប់ព័ត៌មានទាក់ទងនឹងការងារ ដោយរួមបញ្ចូលលក្ខខណ្ឌការងារ សិទ្ធិ និងការទទួលខុសត្រូវក្រោមច្បាប់ការងារ ព័ត៌មានស្តីពីអ្នកផ្តល់សេវាសង្គ្រោះបន្ទាន់ សម្រាប់ជនរងគ្រោះដោយអំពើជួញដូរ | • ការវាយតម្លៃស៊ីជំរៅ នៅក្នុងប្រទេសដែលបានជ្រើសរើស អំពីសេចក្តីត្រូវការព័ត៌មាន ដើម្បីគាំទ្រដល់ការធ្វើចំណាកស្រុករកការងារធ្វើដោយសុវត្ថិភាព និងការពិនិត្យឡើងវិញនូវសម្ភារៈដែលមានស្រាប់ (ពិមុនជាសកម្មភាពដាច់ដោយឡែក)<br>• ចងក្រងសិទ្ធិនិងការទទួលខុសត្រូវក្រោមច្បាប់ការងារនៅក្នុងប្រទេសទាំង ៦ ។ | • រៀបចំសេចក្តីព្រាងកញ្ចប់ព័ត៌មាន<br>• ធ្វើតេស្តសាកល្បង ជាមួយនឹងអ្នកដែលបានវិលត្រឡប់មកវិញ និងជនដែលអាចធ្វើចំណាកស្រុក | • ស្រាវជ្រាវ និងចងក្រងលក្ខខ័ណ្ឌការងារ<br>• ព័ត៌មានដែលត្រូវបានប្រមូលស្តីពីអ្នកផ្តល់សេវាសង្គ្រោះបន្ទាន់ និងអាស័យ ដ្ឋានទាក់ទងរបស់ស្ថានទូត នៅក្នុងប្រទេសទាំងអស់<br>• ពិនិត្យឡើងវិញនិងផលិតជាភាសានៅក្នុងស្រុក |

PPC7 **–សហប្រតិបត្តិការជាមួយវិស័យទេសចរណ៍ រួមទាំងវិស័យឯកជនផងដែរ**

## គោលបំណង

ដើម្បីពង្រីកការចូលរួមចំណែកពីផ្នែកវិស័យទេសចរណ៍ឯកជនសំដៅប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស និង បញ្ហាពាក់ព័ន្ធ។

## ស្ថានភាពរបស់ PPC7 នៅចុងបញ្ចប់នៃ SPA 1

PPC7 (PPC9 នៅក្នុង SPA I) ផ្តោតលើសហប្រតិបត្តិការជាមួយវិស័យទេសចរណ៍ ដោយគូសបញ្ជាក់ចរិក តំបន់នៃវិស័យនេះ ។ ជាក់ច្បាស់ណាស់ដែលថាប្រទេសខមមីតទាំងអស់កំពុងតែមានការវិវត្តន៏ជាខ្លាំងក្នុងការ ជម្រុញ បញ្ហាសុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍ ។ ការស្រាវជ្រាវ នៅដំណាក់កាលទីមួយ បានគូសបញ្ជាក់ តម្រូវការឱ្យមានព័ត៌មានកាន់តែប្រសើរលើចំណងទាក់ទងរវាងវិស័យទេសចរណ៍និងការជួញដូរមនុស្ស។ គំនិតផ្តួច ផ្តើមដោយឡែកបានបង្ហាញថាកិច្ចអភិវឌ្ឍន៏វិស័យទេសចរណ៍ អាចមានឥទ្ធិពលវិជ្ជមាន និងអវិជ្ជមានមកលើការ ជួញដូរមនុស្ស និងបានបង្កើតបញ្ជីផ្ទៀងផ្ទាត់ ប្រឆាំងទៅនឹងការកើនឡើងនូវភាពងាយរងគ្រោះ ទៅក្នុងអំពើ ជយញដូរមនុស្ស ដែលតាមរយៈបញ្ជីនេះ ភាពងាររងគ្រោះត្រូវបានកំណត់រកឃើញ និងដោះស្រាយ។ សម្រាប់ ផែនការអនុតំបន់ទី២ PPC នេះត្រូវ បានពង្រីក ដើម្បីសង្កត់ធ្ងន់លើសេចក្តីត្រូវការចូលរួមកាន់តែច្រើនពី ឧស្សាហកម្មផ្សេងៗរបស់វិស័យឯកជន ក្នុងការដោះស្រាយបញ្ហាជួញដូរមនុស្ស។

## ចំណុចដៅ នៅចុង SPA II

- យុទ្ធសាស្ត្រតំបន់ត្រូវបានអនុម័តស្តីពីកិច្ចសហប្រតិបត្តិការវិស័យទេសចរណ៍ដើម្បីប្រយុទ្ធប្រឆាំងនឹងការ ជួញដូរមនុស្ស ហើយផែនការសកម្មភាពត្រូវបានបង្កើត និងអនុវត្ត
- បង្កើនសហប្រតិបត្តិការជាមួយវិស័យឯកជននៅថ្នាក់តំបន់ និងថ្នាក់ជាតិ ជាមួយនឹងភស្តុតាងអំពីការ វិវត្តន៏ជាក់ស្តែង ដែលគេប្រើជាកត្តាជម្រុញសម្រាប់សហប្រតិបត្តិការបន្ត

| | សកម្មភាព | ជំហានពាក់ព័ន្ធនានា | ការបែងចែកសកម្មភាព | |
|---|---|---|---|---|
| | | | នៅថ្នាក់តំបន់ | នៅតាមប្រទេស |
| 1 | គាំទ្រដល់គមនិតផ្តួចផ្តើមតាមដានឃ្លាំមើលប្រឆាំងនឹងការជួញដូរមនុស្សនៅក្នុងវិស័យទេសចរណ៍ ដោយផ្តោតការយកចិត្តទុកដាក់ខ្លាំងចំពោះផ្នែកផ្សេងៗ (ទេសចរណ៍ បុគ្គលិកធ្វើការងារ និង សហគមន៍ដែលងាយទទួលរងគ្រោះ) | • អនុវត្តន៍គមនិតផ្តួចផ្តើម ផែនការការងារ ដោយគាំទ្រដល់ការប្តេជ្ញាចិត្ត ដែលបានធ្វើនៅសិក្ខាសា លាកាលពីខែវិច្ឆិកា ឆ្នាំ ២០០៧<br>• ត្រួតពិនិត្យនិងវាយតម្លៃ ដោយចងក្រង ឯកសារអំពីការអនុវត្តន៍ល្អ<br>• រៀបចំសិក្ខាសាលាថ្នាក់តំបន់ដើម្បីចែករំលែកបទពិសោធន៍ និងការអនុវត្តន៍ល្អ | • កំណត់អត្តសញ្ញាណដៃគូឯកជនថ្នាក់តំបន់ និងចូលរួមនៅក្នុងការអនុវត្តន៍ផែនការការងារថ្នាក់តំបន់<br>• ផ្តល់ការគាំទ្របច្ចេកទេស និងហិរញ្ញវត្ថុ សម្រាប់ការធ្វើការត្រួតពិនិត្យតាមដានគំនិតផ្តួចផ្តើម និងការគាំទ្រពីសិក្ខាសាលា ថ្នាក់តំបន់ | • ពិនិត្យឡើងវិញនូវព័ត៌មានរបស់ប្រទេសស្តីអំពីទំនាក់ទំនង រវាងវិស័យទេសចរណ៍ និងការជួញដូរមនុស្ស<br>• យុទ្ធនាការផ្សព្វផ្សាយ ព័ត៌មានលើកកំពស់ការយល់ដឹងការបណ្តុះ បណ្តាល និងសកម្មភាពផ្សេងៗទៀត តាមការ ចាំបាច់ |
| 2 | យុទ្ធសាស្ត្រ និង ផែនការសកម្មភា ជាតិ ស្តីពីសហប្រតិបតិការជាមួយវិស័យទេសចរណ៍ ដើម្បីប្រយុទ្ធនឹងការជួញដូរមនុស្ស | • កំណត់អត្តសញ្ញាណដៃគូរផ្នែកឯកជនសំខាន់ៗ នៅក្នុងប្រទេសនីមួយៗ<br>• ធ្វើការស្រាវជ្រាវ លើការកសាង ផែនទីស្តីពីខ្សែសង្វាក់ផ្គត់ផ្គង់ និងតំរូវការខាងការទាមទារឱ្យមានការជួញដូរមនុស្ស និងអាជីវកម ផ្លូវភេទលើកុមារនៅក្នុងផ្នែកឯកជន នៅក្នុងប្រទេសនីមួយៗ<br>• បង្កើតបញ្ជីថ្នាក់តំបន់អំពីជនល្មើសរួមភេទជាមួយនឹងកុមារ នៅក្នុងវិស័យទេសចរណ៍ និង យន្តការចែករំលែកព័ត៌មាន<br>• ធ្វើយុទ្ធធានការលើកកំពង់ការយល់ដឹង<br>• បង្កើតខ្សែទូរស័ព្ទពិសេស និងយន្តការគាំត្រ<br>• កិច្ចសហប្រតិបត្តិការផ្នែកច្បាប់ | ផ្តល់ជំនួយផ្នែកបច្ចេក និងហិរញ្ញវត្ថុ | • រៀបចំសិក្ខាសាលាថ្នាក់ជាតិដើម្បីកំណត់អត្តសញ្ញាណដៃគូសំខាន់ៗ និងដើម្បីបង្កើត និងបង្ហើយយុទ្ធសាស្ត្រនិង ផែនការការងារថ្នាក់ជាតិ<br>• បង្កើតបញ្ជីចុះឈ្មោះថ្នាក់ជាតិ ដើម្បីកត់ត្រាជនល្មើសក្នុងវិស័យទេសចរណ៍រួមភេ ផ្លូវភេទលើកុមារ ដីម្បីចែករំលែកជាមួយប្រទេសដៃគូ |

## PPC8 —-ការគ្រប់គ្រង: ការសម្របសម្រួល ការត្រួតពិនិត្យតាមដាន និងការវាយតម្លៃ

**គោលបំណង**

ដើម្បីធានាឱ្យមានការតាមដានចំពោះការអនុវត្តនីប្រព្រឹត្តទៅដោយប្រសិទ្ធិភាពនូវផែនការសកម្មភាពអនុតំបន់ទី ២ (២០០៨-២០១០) រាប់ទាំងការរាយការណ៍អំពីសកម្មភាពទាន់ពេលវេលា និងត្រឹមត្រូវ និងត្រូវធ្វើការវាយតម្លៃឯករាជ្យ និងតាមមុខសញ្ញាដលបានដៅយក ។

**ស្ថានភាព PPC 8 នៅចុង SPA I**

បន្ថែមលើការបង្កើតប្រព័ន្ធតាមដាន និងវាយតម្លៃសម្រាប់ខមមីត PPC នេះ (PPC 10 នៅក្នុង SPA I) ក៏រួមមានផ្នែកមួយសម្រាប់ជួយសម្រួលការប្រាស្រ័យទាក់ទង និងសហប្រតិបត្តិការប្រកបដោយប្រសិទ្ធិភាពរវាងដៃគូខុសៗគ្នាទាំងអស់ដែលពាក់ព័ន្ធជាមួយនឹងខមមីត ។ នៅក្នុងស្មារតីនៃ PPC នេះ របាយការណ៍ និងរបកគំហើញនៃការវាយតម្លៃត្រូវបានបង្ហាញ ចំពោះរដ្ឋាភិបាល ម្ចាស់ជំនួយ និងភាគីពាក់ព័ន្ធសំខាន់ៗ ដទៃទៀត ។

មាត្រា ៣២ នៃអនុស្សរណៈ**ខមមីត** បានតែងតាំង UNIAP ជាលេខាធិការដ្ឋាននៃដំណើរការ**ខមមីត** ។ លេខាធិការដ្ឋាននេះរួមមានការិយាល័យគ្រប់គ្រងគម្រោង UNIAPនៅបាងកក ប្រទេសថៃ និងការិយាល័យគម្រោង នៅតាមបណ្តាប្រទេសទាំងប្រាំមួយ នៃអនុតំបន់មេគង្គ ។ លេខាធិការដ្ឋានមានភារកិច្ច:

- ជួយសម្រួលការប្រាស្រ័យទាក់ទង និងកសាងផែនការ
- រកមូលនិធិដើម្បីធានាឱ្យផែនការសកម្មភាព**ខមមីត**អនុតំបន់ អាចធ្វើអន្តរាគមន៍ទាន់ពេលវេលា
- រៀបចំកិច្ចប្រជុំមន្ត្រីជាន់ខ្ពស់ប្រចាំឆ្នាំ និងកិច្ចប្រជុំអន្តររដ្ឋមន្ត្រីរៀងរាល់បីឆ្នាំម្តង
- រៀបចំឯកសារស្តីពីលទ្ធផល និងសេចក្តីសម្រេចចិត្តនានា
- រាយការណ៍ជូនដៃគូអភិវឌ្ឍន៍តាមការចាំបាច់
- គ្រប់គ្រង និងកត់ត្រា ថវិកាដែលបានប្រើប្រាស់ ដោយមានការរាយការណ៍នៅក្នុងកិច្ចប្រជុំមន្ត្រីជាន់ខ្ពស់ប្រចាំឆ្នាំ អំពីស្ថានភាពនៃការប្រើប្រាស់ថវិកា
- ផ្សព្វផ្សាយព័ត៌មាន និងធ្វើសន្និសីទសារព័ត៌មានអំពីខមមីត
- ធ្វើការតាមដាន និងវាយតម្លៃផ្ទៃក្នុង និងផ្ទៃក្រៅ អំពីកិច្ចការខមមីត ដោយមានការគាំទ្រពីក្រុមការងារខមមីតថ្នាក់ជាតិ
- ការត្រួតពិនិត្យមើលផ្ទៃក្នុង ទៅលើការគ្រប់គ្រងរបស់លេខាធិការដ្ឋានខមមីត ។

ខណៈដែលភារកិច្ចដូចបានរៀបរាប់ខាងលើ កំពុងតែបន្តជាសេវាកម្ម ដែលផ្តល់ជូនដោយលេខាធិការដ្ឋាន**ខមមីត**

នោះវិភាគទានដ៏សំខាន់បំផុតរបស់លេខាធិការដ្ឋាន**ខចបឹតនេះ** រួមមាន ការសម្របសម្រួល និងការតាមដានដំណើរការ**ខចបឹត** នៅទូទាំងអំឡុងពេលនៃផែនការសកម្មភាពអនុតំបន់ **SPA :**

**ចំណុចដៅ នៅចុងបញ្ចប់របស់ SPA (២០០៨-២០១០)**

- ផែនការតាមដានអន្តរទីភ្នាក់ងារ និងអន្តររដ្ឋាភិបាលដំណើរការ ដោយមានចំណុចដៅ និងពេលវេលារួមគ្នា
- របាយការណ៍តាមដានប្រចាំឆ្នាំ និងការវាយតម្លៃចុងក្រោយនៃឯកសារ**ខចបឹត** SPA ទី ២ (២០០៨-២០១០)
- ការវាយតម្លៃអំពីផលប៉ះពាល់នៃកិច្ចខិតខំប្រឹងប្រែងបង្ការ ការការពារ និងផន្ទាទោស របស់ទីភ្នាក់ងារចម្រុះ នៅទូទាំងអនុតំបន់មេគង្គ

| | សកម្មភាព | ជំហានពាក់ព័ន្ធនានា | ការបែងចែកសកម្មភាព | |
|---|---|---|---|---|
| | | | នៅថ្នាក់តំបន់ | នៅតាមប្រទេស |
| 8.1 | ការរាយការណ៍ | • បង្កើតប្រព័ន្ធមួយនៃការប្រមូល និងវិភាគទិន្នន័យ<br>• ដាក់ឱ្យប្រព័ន្ធ ដំណើរការ<br>• ផ្សព្វផ្សាយលទ្ធផល | របាយការណ៍ឆមាស និងប្រចាំឆ្នាំ ដែលសង្ខេបរាល់ សកម្មភាព ទាំងអស់ដែល បានអនុវត្តនៅគ្រាមុន ជាមួយអនុសាសន៍ជាក់លាក់ សម្រាប់ផែនការសកម្មភាព អនុតំបន់ លើកក្រោយ | របាយការណ៍ស្តីពី សកម្មភាពនីមួយៗ ដែលអនុវត្តនៅក្នុង ផែនការសកម្មភាព អនុតំបន់ |
| 8.2 | ការតាមដាន និងវាយតម្លៃ | • ប្រព័ន្ធតាមដាន និងវាយតម្លៃដែលមានលក្ខណៈស្តង់ដារ ថ្នាក់ដំបន់ត្រូវបានបង្កើត | • ការវាយតម្លៃខាងក្រៅ ចំពោះការ អនុវត្ត SPA<br>• ការវាយតម្លៃខាងក្រៅ ចំពោះ PPC ជ្រើសរើស មួយចំនួន | ការតាមដានជិតស្និទ្ធ ចំពោះការអនុវត្តនីផ្នែកនីមួយៗនៃ PPC |
| 8.3 | ការរកមូលនិធិ | • សំណើផ្តល់មូលនិធិ ចំពោះគម្រោង នានារបស់ខមមីតត្រូវបាន រៀបចំ និងដាក់ជូនម្ចាស់ជំនួយឬដៃគូ ទាំងអស់ពិនិត្យ | បន្តពិភាក្សាជាមួយ ទីភ្នាក់ងារខាងក្រៅ ដើម្បីកំណត់រកការគាំទ្រ ផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេស សម្រាប់សកម្មភាពនានា របស់គម្រោង | បន្តពិភាក្សាជាមួយទីភ្នាក់ងារខាងក្រៅ ដើម្បីកំណត់រកការគាំទ្រផ្នែកហិរញ្ញវត្ថុ និង បច្ចេកទេស សម្រាប់សកម្មភាព នានា របស់គម្រោង |
| 8.4 | ការប្រាស្រ័យទាក់ទង និងកិច្ចការរដ្ឋបាល | • មានតួនាទីជាឆ្នែង សម្របសម្រួល រួមមានការកសាងផែនការ និងការរៀបចំកម្មវិធីសកម្មភាព និងទំនាក់ទំនងជាមួយទីភ្នាក់ងារដៃគូ | ការគ្រប់គ្រងមូលនិធិ | កិច្ចប្រជុំទៀងទាត់ និង តាមការចាំបាច់ នៃក្រុមការងារខមមីត |
| 8.5 | កិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីលើកទីបី ( និងកិច្ចប្រជុំ មន្ត្រីជាន់ខ្ពស់ លើកទី ៦ និងទី ៧ នៃ )) | • ការកសាងផែនការ និងការរៀបចំព្រឹត្តិការណ៍ | ធ្វើការជាមួយរដ្ឋាភិបាល ម្ចាស់ផ្ទះដើម្បីរៀបចំ និង អនុវត្តកិច្ចប្រជុំមន្ត្រីជាន់ ខ្ពស់ និងកិច្ចប្រជុំរដ្ឋមន្ត្រី | រដ្ឋាភិបាលម្ចាស់ផ្ទះធ្វើផែនការនិង អនុវត្ត |

## ពតិមានជាមូលដ្ឋានសម្រាប់ការត្រួតពិនិត្យតាមដាន

ផែនការការត្រួតពិនិត្យតាមដានសម្រាប់ SPA II ផ្អែកចម្បងទៅលើការវិវឌ្ឍន៍របស់ SPA I និងការវិវឌ្ឍន៍ថ្មី ចាប់តាំងពី SPA I ត្រូវបានបង្កើតជាលើកដំបូង ។ ការប្រមូលផ្តុំផែនការត្រួតពិនិត្យតាមដាន គឺជាចំណុចដៅ សម្រាប់គោលគំនិតសំណើគម្រោង PPC នីមួយៗ ដែលជាចំណុចបន្ថែម សំរាប់បង្ហាញឱ្យឃើញនូវការវិវឌ្ឍន៍ ឈានទៅរកការសម្រេចលទ្ធផលរបស់ PPC ។ ចំណុចដៅទាំងនេះត្រូវបានរៀបចំឡើង ដើម្បីវាស់វែង កិច្ចខិតខំប្រឹងប្រែងរួមរបស់ទីភ្នាក់និងក្រសួងជាច្រើន នៅក្នុងប្រទេសនានា នៅពេលដែលពួកគេធ្វើការ ដើម្បីសម្រេចគោលបំណងរួម ។ ចំណុចដៅទាំងនេះ ក៏ត្រូវបានរៀបចំឡើងផ្អែកតាមស្តង់ដារ និងគោលការណ៍ អន្តរជាតិ ដែលគ្រប់គ្រងការបង្ការការផ្តន្ទាទោស និងការការពារមនុស្សដែលត្រូវបានគេជួញដូរ ។

ទិដ្ឋភាពទូទៅនៃចំណុចដៅ និងពេលវេលាពាក់ព័ន្ធរហូតមកដល់ខែធ្នូ ឆ្នាំ២០០៧ មានដូចខាងក្រោម :

<table>
<tr><th colspan="2">សកម្មភាព</th><th>ស្ថានភាពនៃផែនការ សកម្មភាពអនុតំបន់ទី១ ឆ្នាំ ២០០៧</th><th colspan="2">ចំណុចដៅនៃផែនការសកម្មភាពអនុតំបន់ទី ២ ឆ្នាំ ២០០៨-២០១០</th></tr>
<tr><td rowspan="3">គោលនយោបាយនិងកិច្ចប្រតិបត្តិការ</td><td rowspan="2">PPC 2<br>ផែនការសកម្មភាពជាតិ</td><td rowspan="2">1: គ្រប់ NPAs ទាំងអស់ ត្រូវបានបញ្ចប់ និងទទួលការអនុម័តពីរដ្ឋាភិបាល ជាមួយនឹងសេចក្តីព្រាងផែនការអនុវត្តន៍</td><td>3: រាល់ផែនការអនុវត្តន៍ទាំងអស់ ចំពោះ NPAs ត្រូវបានបញ្ចប់ ទទួលការអនុម័ត និងបានទទួល មូលនិធិជាមួយនឹងយន្តការម្រប សម្រួល និងការតាមដាន ដែលមាន ដំណើរការ</td><td>6: យន្តការសម្រប សម្រួលនឹងដំណើរការតាមតួន ាទីខ្លួន ហើយនឹង ត្រូវបានដាក់បញ្ចូល ទៅក្នុង អាណត្តិការងារ និងថវិការបស់ស្ថាប័នរដ្ឋាភិបា ល</td></tr>
<tr><td colspan="2">4: ពង្រឹងការសម្របសកម្មភាពប្រឆាំងការជួញដូរមនុស្សជាមួយ NPAs រួមមាន ភាពស៊ីសង្វាក់គ្នារវាង NPAs និងផែនការអនុវត្តន៍តាមវិស័យ ឬរបស់ទីភ្នាក់ងារ</td></tr>
<tr><td>PPC 3<br>ភាពជាដៃគូ ពហុ និង ទ្វេភាគី</td><td>2: បទពិសោធន៍ថ្នាក់តំបន់ក្នុងការកសាង និង អនុវត្តន៍កិច្ចព្រមព្រៀងសហប្រតិបត្តិកា ទ្វេភាគី ស្តីពីការជួញដូរមនុស្សត្រូវបានចងក្រងជា ឯកសារ និងចែករំលែក</td><td>5: យន្តការសម្របសម្រួលទ្វេភាគីស្តីពី ការជួញដូរមនុស្សត្រូវបានចុះហត្ថលេខា តាមការចាំបាច់ជាមួយនឹងការអនុវត្តន៍ និងការតាមដានដែលមានប្រសិទ្ធិភាព</td><td>7: យន្តការសម្របសម្រួលទ្វេ ភាគី ដំណើរការ និងត្រូវបាន ដាក់បញ្ចូលទៅក្នុងអាណត្តិ ការងារ និងថវិការបស់ រដ្ឋាភិបាល</td></tr>
<tr><td>ក្របខ័ណ្ឌច្បាប់</td><td>PPC 4<br>ក្របខ័ណ្ឌច្បាប់ និង ជំនួយ ច្បាប់ទៅវិញទៅមក និង យុត្តិធម៌</td><td>1: ពង្រឹងការឆ្លើយតបទូទៅ និងការឆ្លើយតប របស់ជំនាញអនុវត្តច្បាប់ប្រឆាំងការជួញដូរ មនុស្ស</td><td colspan="2">(1-ត) ពង្រឹងការឆ្លើយតបទូទៅ និងការឆ្លើយតបរបស់ជំនាញអនុវត្ត ច្បាប់ ប្រឆាំងការជួញដូរមនុស្ស</td></tr>
</table>

| | | | |
|---|---|---|---|
| | | 2: សហប្រតិបត្តិការពហុភាគី និងទ្វេ ភាគី ដែលមានប្រសិទ្ធិភាព រវាងអង្គភាពជំនាញផ្នែកប្រឆាំងការជួញដូរ មនុស្ស | (2-ត) កិច្ចសហប្រតិបត្តិការពហុភាគី និងទ្វេភាគី ព្រមទាំងផ្ទៃក្នុង (ប្រទេស) ដែលមានប្រសិទ្ធិភាព រវាងអង្គភាពជំនាញផ្នែកប្រឆាំងការជួញដូរមនុស្ស |
| | | 3: យុទ្ធសាស្ត្រសម្រាប់ផ្តន្ទាទោសការជួញដូរមនុស្សនៅក្រោមក្របខ័ណ្ឌច្បាប់ ត្រូវបានបង្កើត | |
| | | 4: ប្រទេសនានាបានផ្តល់សច្ចាប័នចំពោះកិច្ចព្រមព្រៀងសំខាន់ៗពាក់ព័ន្ធនឹង ការជួញដូរមនុស្សថ្នាក់អន្តរជាតិ និងថ្នាក់តំបន់ហើយដាក់បញ្ចូលបញ្ញត្តិសំខាន់ៗ ទៅក្នុងច្បាប់ជាតិ | 7: មានការឆ្លើយតបដែលមានការជូនដំណឹង និងការឆ្លើយតបផ្នែកតុលាការ និង ព្រះរាជអាជ្ញាបានសមស្រប |
| | | 5: ក្របខ័ណ្ឌច្បាប់ជាតិ (១) ចាត់ការជួញដូរមនុស្សជាបទឧក្រិដ្ឋ (២) ដាក់ទាសទណ្ឌសមស្រប (៣) ការពារជនរងគ្រោះ (៤) គាំទ្រសាក្សី និង (៥) បង្កើតយុត្តាធិការឱ្យបានទូលាយតាម ដែលអាចធ្វើបាន | |
| | | 6: សន្និសញ្ញាត្យាប័ន និងជំនួយផ្នែកច្បាប់ទៅវិញទៅមក ដោយដាក់បញ្ចូល ឧក្រិដ្ឋកម្មពាក់ព័ន្ធ នឹងការជួញដូរមនុស្ស ទាំងអស់ ការសម្របសម្រួលសហប្រតិបត្តិការស៊ើបអង្កេត និងតុលាការ | |
| ការការពារ | **PPC 5** ការកំណត់អត្តសញ្ញាណកម្មជនរងគ្រោះ ការការពារ ការស្តារ និងការធ្វើសមាហរណកម្ម | 1: គោលការណ៍ណែនាំថ្នាក់តំបន់សម្រាប់ការកំណត់ អត្តសញ្ញាណជនរងគ្រោះ ជម្រកស្នាក់នៅ និងការស្តារនីតិសម្បទា ការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្មដែលឯកភាព ដោយការមូលមតិ និងអនុម័ត ដោ រដ្ឋាភិបាល | 2: ការដាក់ឱ្យដំណើរការថ្នាក់ជាតិនូវគោលការណ៍ណែនាំថ្នាក់តំបន់ស្តីពីការការពារ ត្រូវបានបញ្ចប់ពេញលេញ<br>3: ការផ្លាស់ប្តូរគោលនយោបាយ និងនីតិវិធីទ្វេភាគី និងថ្នាក់ជាតិត្រូវបានអនុវត្ត ដើម្បីដោះស្រាយចំណុចខ្វះចន្លោះសំខាន់ៗក្នុងការកសាងសមត្ថភាពនិងហេដ្ឋារចនាសម្ព័ន្ធផ្នែកកម្មវិធីនៃការបញ្ជូនជនរងគ្រោះត្រឡប់មកវិញ<br>4: ការផ្លាស់ប្តូរគោលនយោបាយ និងនីតិវិធីទ្វេភាគី និងនៅថ្នាក់ជាតិ ត្រូវបានអនុវត្ត ដើម្បីដោះស្រាយបញ្ហាប្រឈមបច្ចុប្បន្នក្នុងការអនុវត្តគោលការណ៍ណែនាំស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះ និង គោលការណ៍ណែនាំអំពីការធ្វើមាតុភូមិនិវត្តន៍ |
| វិធានការបង្ការ | **PPC 6** វិធានការបង្ការ | 1: គោលការណ៍ណែនាំថ្នាក់តំបន់ និង ថ្នាក់ជាតិអំពីការជ្រើសរើសពលករចំណាកស្រុក នៅក្នុងអនុតំបន់មេគង្គត្រូវបានរៀបចំ | 3: ការបង្កើត និងការអនុវត្តន៍គោលការណ៍ណែនាំប្រតិបត្តិថ្នាក់ជាតិ និងយន្តការសម្រាប់ជ្រើសរើសកំលាំងពលកម្ម និងការការពារពលករចំណាកស្រុក .<br>7: ការបណ្តុះបណ្តាល និងការតាមដាន ដែលមានលក្ខណៈជាប្រព័ន្ធនូវការអនុលោមតាមគោលការណ៍ណនាំ ថ្នាក់តំបន់ និង ថ្នាក់ជាតិ |

| | | | |
|---|---|---|---|
| | | | 4: វិធានការដោយផ្ទាល់ដើម្បីកំណត់ចំណុចដៅត្រឹមត្រូវ និងកាត់បន្ថយភាពភាពងាយរងគ្រោះ នៅរគប់តំណាក់កាល ដូចជាក្នុងដំណើរការចំណាកស្រុក និង ដំណើរការជ្រើសរើសពលករ ព្រមទាំងនៅក្នុងកន្លែងធ្វើការ |
| | **PPC 7**<br>សហប្រតិបត្តិការជាមួយវិស័យឯកជន | 2: យុទ្ធសាស្ត្រថ្នាក់តំបន់ស្តីពីសហប្រតិបត្តិការជាមួយវិស័យទេសចរណ៍ត្រូវបាន បង្កើត | 5:យុទ្ធសាស្ត្រថ្នាក់តំបន់ត្រូវបានអនុម័តលើសហប្រតិបត្តិការជាមួយវិស័យទេសចរណ៍ ដើម្បីប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស និងផែនការសកម្មភាព ត្រូវបានបង្កើត និងអនុវត្ត |
| | | | 6: បង្កើនសហប្រតិបត្តិការជាមួយវិស័យឯកជននៅថ្នាក់តំបន់ និងនៅក្នុងប្រទេសទាំងអស់ ជាមួយនឹងភស្តុតាងនៃការវិវត្តន៍ជាក់ស្តែង ដែលប្រើជាកត្តាជំរុញសម្រាប់សហប្រតិបត្តិការបន្ថែម |
| **ផ្នែកបច្ចេកទេស ការតាមដាន និងវាយតម្លៃ** | **PPC 1**<br>ការបណ្តុះបណ្តាលនិងការកសាងសមត្ថភាព | 1: ឯកសារនានាត្រូវបានកែលំអ ចងក្រងជាមេរៀន សម្រាប់ការបណ្តុះបណ្តាលថ្នាក់ជាតិ និងការផ្តល់វិញ្ញាប័ត្រ ជូនគ្រូបង្វឹក | 3: កម្មវិធីសិក្សាដែលត្រូវបានសម្រប ទៅតាមកំរិតក់ជាតិ ជាមួយក្របខ័ណ្ឌនៃគ្រូបង្វឹក និងការបណ្តុះបណ្តាលប្រតិបត្តិតាមការដៅទុកត្រូវបានអនុវត្តស្របតាមការវាយតម្លៃអំពីតម្រូវការ ។<br>ការផ្តល់វិញ្ញាបនប័ត្រចំពោះគ្រូបង្វឹក និងការរៀបចំកម្មវិធីរំលឹកដំណើរការ ។ |
| | **PPC 8**<br>ការសម្របសម្រួលតាមដាន និង វាយតម្លៃ | 2:ផែនការតាមដានអន្តរទីភ្នាក់ងារ និងអន្តររដ្ឋាភិបាលដំណើរការ ទៅតាមចំណុចដៅ ជាមួយនិងពេលវេលា រួមគ្នា | 4: របាយការណ៏តាមដានប្រចាំឆ្នាំនិងការវាយតម្លៃចុងក្រោយ ចំពោះផែនការសកម្មភាព**ខមមីត**អនុតំបន់លើកទី ២ |
| | | | 5:ការវាយតម្លៃឥទ្ធិពលសរុប : កិច្ចខិតខំប្រឹងប្រែងលើការបង្ការ ការការពារ និងការផ្តន្ទាទោសរបស់ទីភ្នាក់ងារចម្រុះ នៅទូទាំងអនុតំបន់មេគង្គ |